ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ០៩ ប្រ.ក.ព

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃសុក្រ ៧កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
# ត្រូវនឹងថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០

នៅព្រឹកថ្ងៃសុក្រ ៧កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង៨និង០០នាទីព្រឹក នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

**១-សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។**
**២-សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។**
**៣-ការអភិវឌ្ឍគម្រោងថាមពលអគ្គិសនីស៊ីងគាដៃលើ អានុភាព១៥០មេហ្គាវ៉ាត់ នៅស្រុកថ្មបាំង ខេត្តកោះកុង និងគម្រោងវិនិយោគអភិវឌ្ឍខ្សែបណ្តាញបញ្ជូនអគ្គិសនី៥០០គីឡូវ៉ុល ពីរាជធានីភ្នំពេញទៅព្រំដែនកម្ពុជា-ឡាវ និងពីបាត់ដំបងទៅព្រំដែនកម្ពុជា-ថៃ។**
**៤-បញ្ហាផ្សេងៗ។**

ក្រោយពីបានស្តាប់របាយការណ៍និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេច៖

**១-សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១**

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ត្រូវបានរៀបចំឡើងនៅក្នុងបរិការណ៍ដែលព្រះរាជាណាចក្រកម្ពុជាបាននិងកំពុងទទួលរងផលប៉ះពាល់អវិជ្ជមានពីជំងឺកូវីដ-១៩ ដែលស្ថានភាពនេះបាននាំមកនូវបញ្ហាប្រឈមនិងហានិភ័យជាច្រើនចំពោះតំបន់និងសកលលោក ដោយបានធ្វើឱ្យមនុស្សរាប់លាននាក់លើពិភពលោកបាត់បង់ការងារ ប្រាក់ចំណូល និងធ្លាក់ចុះក្នុងភាពក្រីក្រ។ ការរាតត្បាតនៃជំងឺកូវីដ-១៩ មិនត្រឹមតែធ្វើឱ្យប្រទេសកម្ពុជាទទួលរងផលប៉ះពាល់ជាអវិជ្ជមានទៅលើបញ្ហាសុខភាពនិងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន និងសមិទ្ធផលសង្គម-សេដ្ឋកិច្ចដែលកម្ពុជាសម្រេចបាននាពេលកន្លងមកដោយលំបាកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនឹងទាញបន្ថយល្បឿនដល់ដំណើរការអភិវឌ្ឍរបស់កម្ពុជា ពិសេសអាចនឹងពន្យារពេលនៃការឈានទៅសម្រេចបាននូវចក្ខុវិស័យរបស់កម្ពុជា ក្នុងការប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ផងដែរ។

ក. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០២១

នាពាក់កណ្ដាលឆ្នាំកន្លងមក សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០២០ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនអវិជ្ជមានក្នុងអត្រា-១,៩% ហើយត្រូវបានព្យាករថានឹងងើបឡើងវិញនៅឆ្នាំ២០២១ ដោយរំពឹងថានឹងសម្រេចបានកំណើនក្នុងរង្វង់៣,៥% ដែលធ្វើឱ្យផ.ស.ស. ថ្លៃបច្ចុប្បន្នស្ថិតក្នុងរង្វង់ ១១៧ ៩៣៩ប៊ីលានរៀល សមមូលនឹងប្រមាណ២៩ ០១៣លានដុល្លារអាមេរិក ស្របពេលដែល ផ.ស.ស. សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់១ ៧៧១ដុល្លារអាមេរិក បើប្រៀបធៀប ១ ៦៨៣ដុល្លារអាមេរិក ក្នុងឆ្នាំ២០២០។ កំណើននេះត្រូវបានគាំទ្រដោយការងើបឡើងវិញនៃវិស័យសេដ្ឋកិច្ចសំខាន់ៗក្នុងឆ្នាំ២០២១ដូចជា៖ វិស័យឧស្សាហកម្មមានកំណើន៨,១% (-២,២%ក្នុងឆ្នាំ២០២០) វិស័យសេវាកម្មមានអត្រាកំណើន៣,៦%(-៣,០%ក្នុងឆ្នាំ២០២០) និងវិស័យកសិកម្មមានអត្រាកំណើន ១,៦%(០,៩% ក្នុងឆ្នាំ២០២០)។

នៅក្នុងឆ្នាំ២០២១ អត្រាអតិផរណាប្រចាំឆ្នាំត្រូវបានប៉ាន់ស្មានថាស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានក្នុងអត្រា៣,១% អត្រាប្ដូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ត្រូវបានប៉ាន់ស្មានថានឹងនៅតែបន្តមានស្ថេរភាពក្នុងរង្វង់៤ ០៦៥រៀលក្នុង១ដុល្លារអាមេរិក ឱនភាពគណនីចរន្ត(រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថារួមតូចបន្តិចមកត្រឹម១៧,៣%នៃផ.ស.ស. ដោយទ្បែកទុនបម្រុងអន្តរជាតិសរុប ត្រូវបានរំពឹងថានឹងកើនឡើងដល់១៦ ៩៨១លានដុល្លារអាមេរិក ដែលធានាការនាំចូលបាន៨ខែ។

ខ. ចំណូលនិងចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២១

ថវិកាឆ្នាំ២០២១ ត្រូវបានរៀបចំនិងវិភាជន៍ដូចតទៅ៖

- ចំណូលថវិកាថ្នាក់ជាតិ៖ ត្រូវបានគ្រោងក្នុងចំនួន ១៩ ៩២៧ ១៨៦លានរៀល (ប្រមាណ ៤ ៩០២ លានដុល្លារអាមេរិក) ត្រូវជា១៦,៩០% នៃផ.ស.ស. ដែលថយចុះ១៧,៣% ធៀបនឹងឆ្នាំ២០២០។ ក្នុងនោះចំណូលចរន្តថ្នាក់ជាតិត្រូវសម្រេចឱ្យបានចំនួន១៩ ៧០៥ ៥៨៣លានរៀល (ប្រមាណ៤ ៨៤៧លានដុល្លារអាមេរិក) ត្រូវជា១៦,៧១%នៃផ.ស.ស. ដែលថយចុះ១៧,៥% ធៀបនឹងឆ្នាំ២០២០។ ចំណូលសារពើពន្ធត្រូវសម្រេចឱ្យបានចំនួន១៧ ៥២០ ០០០លានរៀល (ប្រមាណ៤ ៣០៩លានដុល្លារអាមេរិក) ត្រូវជា១៤,៨៦%នៃផ.ស.ស. ដែលថយចុះ១៦,៩% ធៀបនឹងឆ្នាំ២០២០ ដោយក្នុងនោះចំណូលគយនិងរដ្ឋាករត្រូវបានគ្រោងចំនួន៩ ៤៩៦ ០០០លានរៀល (ប្រមាណ២ ៣៣៦លានដុល្លារអាមេរិក) ត្រូវជា៨,០៥%នៃផ.ស.ស. ដែលថយចុះ១៨,៥% ធៀបនឹងឆ្នាំ២០២០ និងចំណូលពន្ធដារត្រូវបានគ្រោងចំនួន៨ ០២៤ ០០០លានរៀល (ប្រមាណ១ ៩៧៣លានដុល្លារអាមេរិក) ត្រូវជា៦,៨០%នៃផ.ស.ស. ដែលថយចុះ១៥,០% ធៀបនឹងឆ្នាំ២០២០។ ចំណូលមិនមែនសារពើពន្ធត្រូវបានគ្រោងចំនួន២ ១៨៥ ៩៨៣លានរៀល (ប្រមាណ៥៣៧ លានដុល្លារអាមេរិក)។ ក្នុងឆ្នាំ២០២១ រាជរដ្ឋាភិបាលមិនបានដាក់ចេញនូវប្រភេទពន្ធថ្មី ឬបង្កើនអត្រាពន្ធនោះទេ។

ចំណូលមូលធន ត្រូវបានគ្រោងចំនួន៦ ៥៤៥ ៣៥៣លានរៀល (ប្រមាណ១ ៦០៩ លានដុល្លារអាមេរិក) ត្រូវជា៥,៥៥%នៃផ.ស.ស. គឺមានកំណើន០,៧% ធៀបនឹងឆ្នាំ២០២០។

ក្របខ័ណ្ឌថវិកាឆ្នាំ២០២១ មានគោលដៅបង្កើនចំណូលចរន្តថវិការដ្ឋឱ្យបានស្មើនឹង១៨,០% នៃផ.ស.ស. ដែលមានការថយចុះចំនួន៥,៦៣ពិន្ទុភាគរយនៃផ.ស.ស. ធៀបនឹងឆ្នាំ២០២០ តែស្ថិតនឹងសម្រេចបានទាបជាងគោលដៅនៃការប្រមូលចំណូលចរន្តថវិការដ្ឋ ដែលត្រូវបានកំណត់ឱ្យកើនជាមធ្យម០,៣ពិន្ទុភាគរយនៃផ.ស.ស.ក្នុងមួយឆ្នាំ នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣ គឺដោយសារកត្តាសត្យានុម័តនៃការផ្ទុះឡើងនូវជំងឺកូវីដ-១៩ និងគ្រោះមហន្តរាយទឹកជំនន់ក្នុងអំឡុងឆ្នាំ២០២០នេះ។

- ចំណាយថវិកាថ្នាក់ជាតិ៖ ត្រូវបានគ្រោងក្នុងចំនួន ៣០ ៤៩១ ៣៣៦លានរៀល (ប្រមាណ ៧ ៥០០ លានដុល្លារអាមេរិក) ត្រូវជា២៥,៨៥% នៃ ផ.ស.ស. ដែលថយចុះ ១,៩% ធៀបនឹងឆ្នាំ២០២០។ ក្នុងនោះចំណាយចរន្តថ្នាក់ជាតិត្រូវបានកំណត់ឱ្យបានស្ថិតក្នុងកម្រិតចំនួន ១៧ ៤៤៦ ៨៩១លានរៀល (ប្រមាណ៤ ២៥១លានដុល្លារអាមេរិក) ត្រូវជា១៤,៧៩%នៃផ.ស.ស. ដែលថយចុះ៣,៣% ធៀបនឹងឆ្នាំ២០២០។ ចំពោះចំណាយបន្ទុកបុគ្គលិកក្នុងឆ្នាំ២០២១ ដែលរួមមានបៀវត្សមូលដ្ឋានប្រាក់បំណាច់មុខងារ លាភការ រង្វាន់ផ្សេងៗ និងប្រាក់វិភាជន៍សង្គម សម្រាប់ថ្នាក់ដឹកនាំនៃស្ថាប័នសាធារណៈ បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ មន្ត្រីជាប់កិច្ចសន្យា ត្រូវបានគ្រោងចំនួន ៨ ៥៦៥ ៥៧៤ លានរៀល (ប្រមាណ២ ១០៧លានដុល្លារអាមេរិក) សមាមាត្រនឹង៤៩,១%នៃចំណាយចរន្តថ្នាក់ជាតិ ត្រូវជា៧,២៦%នៃផ.ស.ស. និងមានកំណើន០,៣%ធៀបនឹងឆ្នាំ២០២០។ ក្នុងឆ្នាំ២០២១ បៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ នឹងត្រូវរក្សាកម្រិតឆ្នាំ២០២០ ដើម្បីសន្សំថវិកាសម្រាប់ទប់ទល់ការរាតត្បាតនៃជំងឺកូវីដ-១៩ និងគ្រោះមហន្តរាយទឹកជំនន់រដូវវស្សាឆ្នាំ២០២០។ ចំណាយក្រៅបន្ទុកបុគ្គលិកក្នុងឆ្នាំ២០២១ ត្រូវបានគ្រោងចំនួន៨ ៨៨១ ២៦៧លានរៀល (ប្រមាណ ២ ១៨៤លានដុល្លារអាមេរិក) សមាមាត្រនឹង៥០,៩%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា៧,៥៣% នៃផ.ស.ស. និងថយចុះ៦,៥% ធៀបនឹងឆ្នាំ២០២០។

ចំណាយមូលធនថ្នាក់ជាតិត្រូវបានគ្រោងក្នុងចំនួន១៣ ០៤៤ ៩៥៥លានរៀល (ប្រមាណ ៣ ២០៨លានដុល្លារអាមេរិក) មានសមាមាត្រស្មើនឹង៤២,៨% ត្រូវជា១១,០៦%នៃផ.ស.ស. ដែលថយចុះ០,១% ធៀបនឹងឆ្នាំ២០២០ ក្នុងគោលដៅគាំទ្រដល់ការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២១-២០២៣ ជាពិសេសការស្តារនិងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ។

គ. ការកំណត់ពិតាននៃការខ្ចី

ការកំណត់ពិតាននៃការខ្ចី រាជរដ្ឋាភិបាលបានកំណត់ទំហំនៃការខ្ចីប្រាក់ពីដៃគូអភិវឌ្ឍន៍សម្រាប់ឆ្នាំ២០២១ ក្នុងកម្រិត១ ៥០០លានអេសដេអ៊ែ (SDR) គឺកើនឡើង១០០លានSDR ធៀបនឹងឆ្នាំ២០២០ ។

ឃ. ចំណូលនិងចំណាយថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ឆ្នាំ២០២១

- ចំណូលចរន្តថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក៖ ត្រូវបានគ្រោងចំនួន ១ ៥១៨ ៤០៦លានរៀល (ប្រមាណ៣៧៣លានដុល្លារអាមេរិក) មានសមាមាត្រស្មើនឹង៧,១៥% នៃចំណូលចរន្តថវិការដ្ឋ ត្រូវជា១,២៩%នៃផ.ស.ស. មានការថយចុះ៣២,៣% ធៀបនឹងឆ្នាំ២០២០។ ចំណូលសារពើពន្ធត្រូវបានគ្រោងចំនួន ១ ០៥០ ៣២៣លានរៀល (ប្រមាណ២៥៨ លានដុល្លារអាមេរិក) ត្រូវជា០,៨៩% នៃផ.ស.ស. ថយចុះ៤៩,៧% ធៀបនឹងឆ្នាំ២០២០។ ចំណូលមិនមែនសារពើពន្ធត្រូវបានគ្រោងចំនួន៤៦៨ ០៨៣លានរៀល (ប្រមាណ១១៥លានដុល្លារអាមេរិក) ត្រូវជា០,៤០%នៃផ.ស.ស. មានកំណើន១៩៧,៣% ធៀបនឹងឆ្នាំ២០២០។

- ចំណាយថវិការាជធានី ខេត្ត ក្រុង ស្រុក និង ឃុំ សង្កាត់៖ ត្រូវបានគ្រោង ២ ៥៧៨ ៨៥៦ លានរៀល (ប្រមាណ៦៣៩ លានដុល្លារអាមេរិក) មានសមាមាត្រស្មើនឹង ៨,១%នៃចំណាយថវិការដ្ឋសរុប ត្រូវជា២,១៩%នៃផ.ស.ស. មានការថយចុះ២២,៥% ធៀបនឹងឆ្នាំ២០២០។ នៅក្នុងនោះ ចំណាយចរន្តត្រូវបានគ្រោងចំនួន២ ៣៦៤ ៦៥០លានរៀល (ប្រមាណ៥៨១លានដុល្លារអាមេរិក) មានសមាមាត្រស្មើនឹង១២,៦%នៃចំណាយចរន្តថវិការដ្ឋសរុប ត្រូវជា២,០%នៃផ.ស.ស. ថយចុះ១៧,៥% ធៀបនឹងឆ្នាំ២០២០។ ក្នុងឆ្នាំ២០២១ ប្រាក់បំណាច់របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ក៏ដូចជាក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិ នឹងត្រូវបានរក្សាស្មើនឹងកម្រិតឆ្នាំ២០២០។

ចំណាយមូលធនរបស់រាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ត្រូវបានគ្រោងចំនួន ២១៤ ២០៦លានរៀល (ប្រមាណ៥២លានដុល្លារអាមេរិក) មានសមាមាត្រស្មើនឹង៣,២%នៃចំណាយមូលធនដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវជា០,១៨%នៃផ.ស.ស.។

ង. តុល្យភាពថវិកាឆ្នាំ២០២១

ក្នុងក្របខ័ណ្ឌថវិកាខាងលើ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលនឹងអាចរក្សាអតិរេកថវិកាចរន្ត ឱ្យបានក្នុងកម្រិតប្រមាណ២,១០%នៃផ.ស.ស. នៅឆ្នាំ២០២១ ធៀបនឹងច្បាប់ឆ្នាំ២០២០ ដែលមាន៥,៧២%នៃផ.ស.ស.។

ថវិកាឆ្នាំ២០២១ គឺជាថវិកាប្រយុទ្ធការពារអាយុជីវិតប្រជាជន រក្សាលំនឹងសង្គម-សេដ្ឋកិច្ច និងជីវភាពរបស់ប្រជាជន ព្រមជាមួយនឹងការត្រៀមធនធានឆ្ពោះទៅស្តារនិងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ នៅក្រោយពេលស្រាកស្រាន្តពីវិបត្តិជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីថ្មី ដើម្បីធានាសុខសន្តិភាព ស្ថិរភាពសង្គមនិងចីរភាពនៃកំណើនសេដ្ឋកិច្ច ព្រមទាំងភាពប្រកួតប្រជែងរបស់កម្ពុជា ជាមួយនឹងការបន្តលើកស្ទួយសុខុមាលភាពរបស់ប្រជាជន។

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ត្រូវបានរៀបចំឡើងដោយមាន៦ជំពូកនិង១៥មាត្រា ហើយត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្រ្តី។

## ២-សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩

សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ គឺជាការឆ្លុះបញ្ចាំងអំពីលទ្ធផលនៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។

ការអនុវត្តថវិកាឆ្នាំ២០១៩ ពិតជាសម្រេចបានតាមការប្រសិទ្ធនាមថាជា «ថវិកាយុទ្ធសាស្ត្រនៃការរក្សាការពារសមិទ្ធផលដែលសម្រេចបានដោយលំបាកក្នុងពេលកន្លងមក និងការបន្តបុកគ្រឹះថ្មីៗសម្រាប់គាំទ្រដល់ការសម្រេចបាននូវគោលដៅសំខាន់ៗ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ដើម្បីបន្តរក្សាសន្តិភាព ស្ថិរភាព ក៏ដូចជាទ្រទ្រង់នូវដំណើរការវិវឌ្ឍឈានឡើងរបស់កម្ពុជាលើវិថីនៃការអភិវឌ្ឍប្រកបដោយគុណភាពនិងចីរភាពតទៅមុខឥតឈប់ឈរ»។

លទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០១៩ រួមមាន៖

- **ចំណូលថវិការដ្ឋ** (ថវិកាថ្នាក់ជាតិនិងថវិកាថ្នាក់ក្រោមជាតិ) ឆ្នាំ២០១៩ អនុវត្តបានចំនួន ៣៤ ៥៤៣ ៩០៦,១ លានរៀល ស្មើនឹង ៣១,៩០%នៃផ.ស.ស. គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ២៣,១% ដោយក្នុងនោះចំណូលក្នុងប្រទេសអនុវត្តបានចំនួន២៧ ៩១៦ ៥៥០,៨លានរៀល ស្មើនឹង២៥,៣៨%នៃផ.ស.ស. គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ៣០,៨% និងចំណូលមូលធនក្រៅប្រទេសអនុវត្តបានចំនួន ៥ ៤៧៥ ៦៧៣,៨លានរៀល ស្មើនឹង៤,៩៨%នៃផ.ស.ស. គឺទាបជាងច្បាប់ហិរញ្ញវត្ថុ១,៨%។
- **ចំណាយថវិការដ្ឋ** (ថវិកាថ្នាក់ជាតិនិងថវិកាថ្នាក់ក្រោមជាតិ) ឆ្នាំ២០១៩ អនុវត្តបានចំនួន ២៨ ៦៧៦ ៦៣៩,៨ លានរៀល ស្មើនឹង ២៦,០៧%នៃផ.ស.ស. គឺទាបជាងច្បាប់ហិរញ្ញវត្ថុ១,៥% ដោយក្នុងនោះចំណាយចរន្តថវិការដ្ឋ(ថវិកាថ្នាក់ជាតិនិងថវិកាថ្នាក់ក្រោមជាតិ) អនុវត្តបានចំនួន ១៨ ៧៦៩ ៩១៤,៥លានរៀល ស្មើនឹង១៧,០៦%នៃផ.ស.ស. គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ១,៧%។

លទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០១៩ បានបង្ហាញឱ្យឃើញថារាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវសូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ចនិងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ជាអាទិ៍ កំណើនសេដ្ឋកិច្ចសម្រេចបាន៧,១% ដូចការគ្រោងទុក។ ផ.ស.ស. សម្រាប់មនុស្សម្នាក់ៗសម្រេចបាន ១ ៧០០ដុល្លារអាមេរិក អតិផរណាជាមធ្យមប្រចាំឆ្នាំ២០១៩ មាន១,៨% ធៀបនឹងការគ្រោងទុកគឺក្នុងរង្វង់៣,១% អត្រាប្តូរប្រាក់ជាមធ្យម៤ ០៥៥រៀលក្នុង១ដុល្លារអាមេរិក ធៀបនឹងការគ្រោង ៤ ០៣៧រៀល។ ចំពោះក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ កំណើនចំណូលចរន្តសរុបសម្រេចបាន ៣,០១ពិន្ទុភាគរយនៃផ.ស.ស. ធៀបនឹងគោលដៅ០,៥៧ពិន្ទុភាគរយនៃផ.ស.ស.។ ដោយសារ

លទ្ធផលនៃការប្រមូលចំណូលបានខ្ពស់ និងការអនុវត្តចំណាយថវិកាប្រកបដោយប្រសិទ្ធភាព រាជរដ្ឋាភិបាលមិនត្រឹមតែពុំបានប្រើប្រាស់ប្រាក់សន្សំក្នុងបញ្ញើរាជរដ្ឋាភិបាលដែលត្រូវបានគ្រោងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ចំនួន៨០៥ ០០០លានរៀលប៉ុណ្ណោះទេ តែថែមទាំងសម្រេចបាននូវអតិរេកពីការអនុវត្តថវិកាក្នុងឆ្នាំសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ចំនួន ៣ ៧៣៥ ២៦៧,៥លានរៀលទៀត ដែលត្រូវបានដាក់បញ្ចូលជាប្រាក់សន្សំបន្ថែមសម្រាប់រួមចំណែកគាំទ្រដល់ការអនុវត្តអាទិភាពគោលនយោបាយផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល។

សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ត្រូវបានរៀបចំឡើងដោយមាន៣ជំពូកនិង២២មាត្រា ហើយត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

**៣-ការអភិវឌ្ឍគម្រោងវារីអគ្គិសនីស្ទឹងតាតៃលើ អានុភាព១៥០មេហ្គាវ៉ាត់ នៅស្រុកថ្មបាំង ខេត្តកោះកុង និងគម្រោងវិនិយោគអភិវឌ្ឍសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនី ៥០០គីឡូវ៉ុល ពីរាជធានីភ្នំពេញទៅព្រំដែនកម្ពុជា-ឡាវ និងពីបាត់ដំបងទៅព្រំដែនកម្ពុជា-ថៃ**

បន្ទាប់ពីរាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យក្រុមហ៊ុន China National Heavy Machinery Corporation (CHMC) ធ្វើការវិនិយោគអភិវឌ្ឍគម្រោងវារីអគ្គិសនីស្ទឹងតាតៃលើ និងឱ្យក្រុមហ៊ុន SchneiTec Co., Ltd ធ្វើការវិនិយោគអភិវឌ្ឍគម្រោងខ្សែបណ្តាញបញ្ជូនតង់ស្យុង៥០០គីឡូវ៉ុល ២ខ្សែ ពីភ្នំពេញទៅព្រំដែនកម្ពុជា-ឡាវ និងពីបាត់ដំបងទៅព្រំដែនកម្ពុជា-ថៃ គណៈកម្មការចរចាអន្តរស្ថាប័នត្រូវបានបង្កើតដែលដឹកនាំដោយក្រសួងរ៉ែនិងថាមពល និងមានការចូលរួមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា។ គណៈកម្មការនេះបានធ្វើការពិនិត្យលើការសិក្សាសមិទ្ធិលទ្ធភាព និងធ្វើការចរចាលើការវិនិយោគគម្រោងទាំង៣ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីបន្ថែម បំពេញតម្រូវការចាំបាច់ដែលវិស័យអគ្គិសនីត្រូវការជាបន្តបន្ទាប់។

គម្រោងវារីអគ្គិសនីស្ទឹងតាតៃលើ គឺជាគម្រោងមួយដែលមានសក្តានុពលវារីអគ្គិសនីប្រើប្រភពទឹករបស់ស្ទឹង២គឺស្ទឹងកែបនិងស្ទឹងតាតៃ ដោយសាងសង់ទំនប់២ កាត់ស្ទឹងទាំង២ បង្កើតជាអាងស្តុកទឹក២ ភ្ជាប់គ្នាទៅវិញទៅមក ដោយរូងក្រោមដីបង្ហូរទឹកក្រោមដី។ ប្រភពទឹកដែលតភ្ជាប់គ្នានេះ គ្រោងទម្លាក់យកមកផលិតថាមពលអគ្គិសនីនៅអគារថាមពលដែលមានអានុភាពសរុប១៥០មេហ្គាវ៉ាត់ ឋិតនៅចម្ងាយ១៣គីឡូម៉ែត្រ ក្រោមទំនប់ទឹកស្ទឹងកែបតាមបំពង់ទូណែលបង្ហូរទឹកក្រោមដី។ គម្រោងនេះនឹងត្រូវធ្វើឡើងក្រោមរូបភាពជាគម្រោងវិនិយោគសាងសង់-ដំណើរការ-ផ្ទេរ (Build-Operation-Transfer) ក្នុងទំហំវិនិយោគសរុបចំនួន៣៨៩ ៩១៨ ០០៥ ដុល្លារអាមេរិក។ គម្រោងនេះផ្តល់សម្បទានរយៈពេល៣៩ឆ្នាំ ក្នុងនោះ៤ឆ្នាំសម្រាប់ការសាងសង់ និង៣៥ឆ្នាំសម្រាប់ការធ្វើអាជីវកម្ម។ បរិមាណមូលដ្ឋាននៃថាមពលអគ្គិសនីផលិតប្រចាំឆ្នាំលក់ឱ្យអគ្គិសនីកម្ពុជាគឺជាមធ្យម៥២៧លានគីឡូវ៉ាត់ម៉ោង ហើយលក់ក្នុងតម្លៃ៧,៩២សេនអាមេរិកក្នុង ១គីឡូវ៉ាត់ម៉ោង។

គម្រោងវិនិយោគអភិវឌ្ឍសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនី៥០០គីឡូវ៉ុល ពីរាជធានីភ្នំពេញទៅព្រំដែនកម្ពុជា-ឡាវ មានប្រវែង២៩៩,៥២គីឡូម៉ែត្រ និងពីបាត់ដំបងទៅព្រំដែនកម្ពុជា-ថៃ មានប្រវែង១០៧គីឡូម៉ែត្រ គឺជាគម្រោងវិនិយោគដែលបញ្ជូនប្រភពអគ្គិសនីនាំចូលពីប្រទេសឡាវ និងប្រទេសថៃមកក្នុងប្រព័ន្ធបណ្តាញជាតិ ដើម្បីបំពេញឱ្យបានគ្រប់គ្រាន់ និងឱ្យមានប្រភពអគ្គិសនីចម្រុះរក្សាសុវត្ថិភាពនៃការផ្គត់ផ្គង់នៅក្នុងកម្ពុជា។ គម្រោងវិនិយោគទាំងពីរមានលក្ខណៈស្រដៀងគ្នាស្ទើរតែទាំងស្រុង ដែលក្នុងនោះរូបភាពវិនិយោគនៃគម្រោងទាំងពីរនេះគឺ សាងសង់-ដំណើរការ-ផ្ទេរ

(Build-Operation-Transfer)។ សម្រាប់គម្រោងវិនិយោគអភិវឌ្ឍខ្សែបណ្ដាញបញ្ជូនអគ្គិសនី៥០០គីឡូវ៉ុល ពីភ្នំពេញទៅព្រំដែនកម្ពុជា-ឡាវ មានរយៈពេលសម្បទានសរុប២៨ឆ្នាំ ក្នុងនោះសាងសង់៣ឆ្នាំ និងអាជីវកម្ម២៥ឆ្នាំ និងមានទំហំវិនិយោគសរុបចំនួន៣៣០ ៩៦៦ ៥៨៨ដុល្លារអាមេរិក។ ចំណែកគម្រោងវិនិយោគអភិវឌ្ឍខ្សែបណ្ដាញបញ្ជូនអគ្គិសនី៥០០គីឡូវ៉ុលពីបាត់ដំបងទៅព្រំដែនកម្ពុជា-ថៃ មានរយៈពេលសម្បទានសរុប២៧ឆ្នាំ ក្នុងនោះសាងសង់២ឆ្នាំនិងអាជីវកម្ម២៥ឆ្នាំ និងមានទំហំវិនិយោគសរុបចំនួន១១០ ៩៨៨ ៩១២ដុល្លារអាមេរិក។

ផលប្រយោជន៍នៃការអនុវត្តគម្រោងរោងចក្រអគ្គិសនីស្ទឹងតាតៃលើ និងគម្រោងវិនិយោគអភិវឌ្ឍសាងសង់ខ្សែបណ្ដាញបញ្ជូនអគ្គិសនី៥០០គីឡូវ៉ុល ពីរាជធានីភ្នំពេញទៅព្រំដែនកម្ពុជា-ឡាវ និងពីបាត់ដំបងទៅព្រំដែនកម្ពុជា-ថៃ មិនត្រឹមតែផ្ដល់នូវអានុភាពអគ្គិសនីបន្ថែម និងបញ្ជូនប្រភពអគ្គិសនីពីបណ្ដាញជាតិទៅឱ្យតំបន់ដាច់ស្រយាលក្បែរព្រំដែនកម្ពុជា-ឡាវ និងព្រំដែនកម្ពុជា-ថៃប៉ុណ្ណោះទេ ប៉ុន្តែគម្រោងវិនិយោគទាំងនេះក៏នឹងផ្ដល់ជូនរដ្ឋនូវចំណូលពន្ធរួមមាន ពន្ធលើប្រាក់ចំណូល ពន្ធកាត់ទុកលើចំណាយការប្រាក់ ពន្ធកាត់ទុកលើការបែងចែកភាគលាភ ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុកលើការជួលនានា និងពន្ធដោយប្រយោលដទៃទៀតក្នុងរយៈពេលនៃអាណត្តិប្រតិបត្តិការអាជីវកម្មនៃគម្រោងវិនិយោគនីមួយៗ។

ការអភិវឌ្ឍគម្រោងរោងចក្រអគ្គិសនីស្ទឹងតាតៃលើ អានុភាព១៥០មេហ្គាវ៉ាត់ នៅស្រុកថ្មបាំង ខេត្តកោះកុង និងគម្រោងវិនិយោគអភិវឌ្ឍសាងសង់ខ្សែបណ្ដាញបញ្ជូនអគ្គិសនី៥០០គីឡូវ៉ុល ពីរាជធានីភ្នំពេញទៅព្រំដែនកម្ពុជា-ឡាវ និងពីបាត់ដំបងទៅព្រំដែនកម្ពុជា-ថៃ ត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

**៤-បញ្ហាផ្សេងៗ៖**

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា៖

- រាជរដ្ឋាភិបាលសូមថ្លែងអំណរគុណដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលរាជធានី ខេត្ត ព្រមទាំងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលបាននិងកំពុងជួយសង្គ្រោះប្រជាពលរដ្ឋដែលរងគ្រោះក្នុងកំឡុងគ្រោះទឹកជំនន់រដូវវស្សាឆ្នាំ២០២០នេះ ពិសេសត្រូវបន្តបង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់ និងចាត់វិធានការចាំបាច់នានាដើម្បីជួយសង្គ្រោះអាយុជីវិតប្រជាពលរដ្ឋនៅតាមភូមិសាស្ត្រដែលទទួលខុសត្រូវឱ្យបានទាន់ពេលវេលា។

- ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលរាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់លើការស្ដារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលបានខូចខាតដោយគ្រោះមហន្តរាយទឹកជំនន់ ជាអាទិ៍ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវលំ និងប្រព័ន្ធធារាសាស្ត្រនានាជាដើម នៅក្រោយពេលដែលស្ថានភាពទឹកជំនន់មានភាពធូរស្រាលនិងស្រកអស់ទៅ។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១២និង២២នាទី។

ថ្ងៃសុក្រ ៧កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០